# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងពាណិជ្ជកម្ម**

លេខ ១១៧ ព.ណ.បស..ប្រក

# ប្រកាស
## ស្តីពី
## ការបង្កើតអនុគណៈកម្មការត្រួតពិនិត្យ ដំណើរការសាងសង់ផ្សារគំរូព្រំដែនកម្ពុជា(ផ្សារដារ)

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ១៣១ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងពាណិជ្ជកម្ម
- បានឃើញប្រកាសលេខ ២៨៥ ពណ.អទផ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការបង្កើតគណៈកម្មការគ្រប់គ្រងគម្រោងសម្រាប់អនុវត្តការសាងសង់ផ្សារគំរូព្រំដែនកម្ពុជា វៀតណាម
- យោងតាមការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម។

## សម្រេច

**ប្រការ ១**.- ត្រូវបានបង្កើត អនុគណៈកម្មការត្រួតពិនិត្យដំណើរការសាងសង់ផ្សារគំរូព្រំដែនកម្ពុជា វៀតណាម (ផ្សារដារ) ស្ថិតនៅភូមិដារកណ្តាល ឃុំដារ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **វ៉េង សុធី** | អនុរដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម | ប្រធាន |
| ២-ឯកឧត្តម | **ប៉ែន កុសល្យ** | អភិបាលរងខេត្តត្បូងឃ្មុំ | អនុប្រធាន |
| ៣-ឯកឧត្តម | **អ៊ុក ទី** | អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៤-លោក | **ស៊ុត តារា** | អគ្គនាយករង នៃអគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម | អនុប្រធាន |

៥-លោក **នួន ច័ន្ទរិទ្ធ** អគ្គនាយករង នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុប្រធាន

៦-លោក **ប៉ាក់ ចាន់ផល** អគ្គនាយករង នៃអគ្គនាយកដ្ឋានសំណង់ នៃ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អនុប្រធាន

៧-លោក **គង់ ពុទ្ធារ៉ា** អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ សមាជិក

៨-លោក **ឈាវ ផា** ប្រធាននាយកដ្ឋានអភិវឌ្ឍន៍ទីផ្សារ នៃក្រសួងពាណិជ្ជកម្ម សមាជិក

៩-លោក **តូច សុខន** ប្រធានមន្ទីរពាណិជ្ជកម្មខេត្តត្បូងឃ្មុំ សមាជិក

១០-លោក **អ៊ុច សារិន** អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍ទីផ្សារនៃក្រសួងពាណិជ្ជកម្ម សមាជិក

១១-លោក **ប៉ុច សុជារិទ្ធិ** ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម និង សំណង់ខេត្តត្បូងឃ្មុំ សមាជិក

១២-លោក **អ៊ុំ វាសនា** ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តត្បូងឃ្មុំ សមាជិក

១៣-លោក **ហ៊ឹង ចក់** អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍ទីផ្សារនៃក្រសួងពាណិជ្ជកម្ម សមាជិក

១៤-លោក **ប៉ុន ប៊ុនធឿន** ប្រធានមន្ទីររ៉ែ និងថាមពល ខេត្តត្បូងឃ្មុំ សមាជិក

១៥-លោក **ហួរ ពិសិដ្ឋ** ប្រធានមន្ទីរបរិស្ថាន ខេត្តត្បូងឃ្មុំ សមាជិក

១៦-លោក **ប៊ិញ ឈាងហន់** ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តត្បូងឃ្មុំ សមាជិក

១៧-លោក **គិរី រិន្ទ** ប្រធានមន្ទីរសាធារណៈការ និងដឹកជញ្ជូន ខេត្តត្បូងឃ្មុំ សមាជិក

១៨-លោក **ចេង ប៊ុណ្ណារ៉ា** អភិបាល នៃគណៈអភិបាលស្រុកមេមត់ ខេត្តត្បូងឃ្មុំ សមាជិក

១៩-លោក **នូ ស៊ីថា** ប្រធានសាខាគយ និងរដ្ឋាករ ខេត្តត្បូងឃ្មុំ សមាជិក

២០-លោក **មាស មោរ៉ា** ប្រធានសាខាកាំកុងត្រូល ខេត្តត្បូងឃ្មុំ សមាជិក

២១-លោក **ឯម បញ្ញារិទ្ធ** ប្រធានច្រកដារ ខេត្តត្បូងឃ្មុំ សមាជិក

២២-លោកស្រី **ចាន់ ស៊ីវណ្ណៈ** ប្រធានការិយាល័យយុទ្ធសាស្ត្រជំរុញទីផ្សារ សមាជិក

២៣-លោកវរសេនីយ៍ឯក **ជិន សាកែម** ប្រធាននការិយាល័យអន្តោប្រវេសន៍ខេត្តត្បូងឃ្មុំ សមាជិក

២៤-លោក **ឡុញ នាន** ប្រធានការិយាល័យភូមិបាលស្រុកមេមត់ ខេត្តត្បូងឃ្មុំ សមាជិក

២៥-លោក **ឡេង សំនិត** ប្រធានការិយាល័យកាំកុងត្រូលច្រកដារ ខេត្តត្បូងឃ្មុំ សមាជិក

២៦-លោក **យឹម វណ្ណៈ** ប្រធានការិយាល័យគយ ច្រកដារ ខេត្តត្បូងឃ្មុំ សមាជិក

២៧-លោក **ចាន់ ធីរ៉ាវុធ** អនុប្រធានការិយាល័យយុទ្ធសាស្ត្រជំរុញទីផ្សារ សមាជិក

២៨-លោក **គង់ លី** មន្ត្រីការិយាល័យយុទ្ធសាស្ត្រជំរុញទីផ្សារ សមាជិក

**ប្រការ ២**.- អនុគណៈកម្មការនេះ មានភារកិច្ចដូចខាងក្រោម៖

- ចុះតាមដានវឌ្ឍនភាពនៃការសាងសង់ផ្សារគំរូព្រំដែនកម្ពុជា (ផ្សារដារ)
- ត្រួតពិនិត្យគុណភាពសំណង់ដោយអនុលោមតាមប្លង់មេដែលភាគីកម្ពុជា វៀតណាម បានឯកភាព
- រៀបចំរបាយការណ៍ពីវឌ្ឍនភាពនៃការសាងសង់ជូនគណៈកម្មការគ្រប់គ្រងសម្រាប់អនុវត្តការសាងសង់ផ្សារគំរូព្រំដែនកម្ពុជា-វៀតណាម
- អនុគណៈកម្មការនេះមានសិទ្ធិ បង្កើតក្រុមការងាររបស់ខ្លួនតាមតម្រូវការ ដោយមានការឯកភាព ពីប្រធានគណៈកម្មការគ្រប់គ្រងសម្រាប់អនុវត្តការសាងសង់ផ្សារគំរូព្រំដែនកម្ពុជា-វៀតណាម។

**ប្រការ ៣**.- ប្រកាសលេខ០០៩ ពណ.អរជ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៨ ស្តីពីការបង្កើតអនុគណៈកម្មការត្រួតពិនិត្យដំណើការសាងសង់ផ្សារព្រំដែនកម្ពុជា (ផ្សារដារ) ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៤**.- នាយកខុទ្ទកាល័យ គណៈកម្មការគ្រប់គ្រងសម្រាប់អនុវត្តការសាងសង់ផ្សារគំរូព្រំដែន កម្ពុជា-វៀតណាម អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកជំរុញពាណិជ្ជកម្ម អភិបាលនៃគណៈអភិបាលខេត្តត្បូងឃ្មុំ ប្រធានគ្រប់អង្គភាពពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ឲ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃព្រហស្បតិ៍ ១២ ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១២ ខែមេសា ឆ្នាំ២០១៨
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន-សូរស័ក្តិ**

**<u>ចម្លងជូន:</u>**

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងរ៉ែ និងថាមពល
- ក្រសួងបរិស្ថាន
- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
- ស្ថានឯកអគ្គរាជទូតប្រចាំនៅសាធារណៈរដ្ឋសង្គមនិយមវៀតណាម
- រដ្ឋបាលខេត្តត្បូងឃ្មុំ
- មន្ទីរពាណិជ្ជកម្មខេត្តត្បូងឃ្មុំ
- គ្រប់សមាជិកគណៈកម្មការអន្តរក្រសួង
- ដូចប្រការ ៤ " ដើម្បីអនុវត្ត "
- ឯកសារ-កាលប្បវត្តិ